# អំពីកុំព្យូទ័រ

ពាក្យថា Computer មកពីពាក្យថា Compute ដែលមានន័យថា គណនា Calculate ដូចនេះ ម៉ាស៊ីន កុំព្យូទ័រជា ឧបករណ៍មួយសំរាប់គណនា ។ ក្រោយ មកដោយសារមានការអភិវឌ្ឍន៍ និង ឆ្នៃ ប្រឌិត កុំព្យូទ័រអាចជួយធ្វើការមនុស្ស បានជាង៩០ % ។
សរុបសេចក្តីមកវិញ ពាក្យថា Computer នេះគឺមានន័យថាវាជា ម៉ាស៊ីន ដែលមានតួនាទីក្នុង ការគណនា ការគ្រប់គ្រង ការស្វែងរក និង ដំណើរការទិន្នន័យ។








# អត្ថប្រយោជន៍កុំព្យូទ័រ

- វាយអត្ថបទ ផ្ញើរបាយការណ៍ និងគណនាផ្សេងៗ
- គូសប្លង់ (ប្លង់ដី អគារ) គូសផែនទី





# អត្ថប្រយោជន៍កុំព្យូទ័រ

- គ្រប់គ្រង ធ្វើស្ថិតិ វិភាគ និងព្យាករណ៍ទិន្នន័យ
- រក្សាទុកឯកសារដោយសុវត្ថិភាព





# អត្ថប្រយោជន៍កុំព្យូទ័រ

- ធ្វើឲ្យមនុស្សទូទាំងពិភពលោកអាចទំនាក់ទំនងគ្នាបាន
- លេងល្បែងកម្សាន្ត (Gaming) ជជែកកម្សាន្ត (Chatting) ...
- ជាពិសេសគឺជួយជំរុញការការងារផ្សេងៗរបស់យើងបានយ៉ាងលឿន





# អត្ថប្រយោជន៍កុំព្យូទ័រ







# អត្ថប្រយោជន៍កុំព្យូទ័រ

អត្ថប្រយោជន៍នៃ Computer ធ្វើឲ្យសកលលោកមានការរីកចម្រើនឆាប់រហ័ស។

- ដំណើរការទិន្នន័យធំៗ ក្នុងល្បឿនលឿន....
- គ្រប់គ្រងទិន្នន័យយ៉ាងស្ទាត់ជំនាញ ការស្វែរកទិន្នន័យបានរហ័សទាន់ចិត្ត...
- កាត់បន្ថយពេលវេលាក្នុងការស្វែងរកទិន្នន័យ...
- កាត់បន្ថយការកត់ត្រាលើក្រដាស...
- អាចរក្សារទុកទិន្នន័យយ៉ាងច្រើននៅលើ Computer និងកាត់បន្ថយកាកសំណល់...
- ជួយរៀបចំទិន្នន័យ និងស្វែងយល់តាមរយៈព័ត៌មាន...
- អាចភ្ជាប់អ្នកទៅនឹង Internet អាចឲ្យយើងស្វែងរក រូបភាព មេរៀន វិឌីអូ ឯសារ តាម Google, YouTube អាចផ្សព្វផ្សាយ ផលិតផលតាម Internet ដោយតាមរយៈក្រុមហ៊ុនធំៗ

# អត្ថប្រយោជន៍កុំព្យូទ័រ

នៅលើពិភពលោក ក្នុងវិស័យ Online ហើយក៏អាចស្វែងរកប្រាក់ចំណូលតាម Online វិញដែរ។

ហើយ Computer គេប្រើស្ទើរតែគ្រប់វិស័យមានដូចជា៖

- វិស័យអប់រំ (Education)
- វិស័យកសិកម្ម (Agriculture)
- វិស័យឧស្សាហកម្ម (Industries)
- វិស័យពាណិជ្ជកម្ម (Practice)
- វិស័យសំណង់ (Engineering)
- វិស័យ សុខាភិបាល (Health) ជាច្រើនទៀត។ល។

បច្ចុប្បន្នគ្រប់មុខវិជ្ជាទាំងអស់ នៅតាមមហាវិទ្យាល័យ ដូចជា Marketing, Accounting, Human Research, Management, ត្រូវបានផ្សារភ្ជាប់ទៅនឹងបច្ចេកវិទ្យាព័ត៌មានវិទ្យា (Information Technology) ដែលជាតំរូវការចាំបាច់សំរាប់អ្នកសិក្សា។ ដើម្បីការងារទៅអនាគតរបស់ខ្លួនអ្នកដែល សិក្សាលើជំនាញ ផ្សេងៗ គឺត្រូវចេះប្រើប្រាស់កុំព្យូទ័រ ជាពិសេសការសិក្សាកុំព្យូទ័រដែលទាក់ទងទៅនឹងជំនាញរបស់ខ្លួនផ្ទាល់។

ដូចច្នេះការសិក្សាពីវិទ្យាសាស្រ្តកុំព្យូទ័រ គឺវាមានសារៈសំខាន់ណាស់ក្នុងការបំរើការងារគ្រប់ វិស័យទាំងអស់នៅក្នុងសង្គមជាពិសេសគឺដើម្បីប្រែក្លាយការងារទាំងឡាយដែលមនុស្សយើងធ្លាប់ធ្វើ ដោយដៃឲ្យក្លាយទៅជាការងារដែលអនុវត្តន៍ដោយម៉ាស៊ីនកុំព្យូទ័រ។

# សារៈប្រយោជន៍កុំព្យូទ័រ

សព្វថ្ងៃនេះ Computer ត្រូវបានប្រើប្រាស់សំរាប់គ្រប់ស្ថាប័នរដ្ឋ អង្គការ និង ក្រុមហ៊ុន។ Computer ត្រូវបានប្រើប្រាស់លើវិស័យទាំងអស់ដូចជាៈ

**វិស័យអប់រំ**ៈ គេប្រើប្រាស់ Computer ដើម្បីគ្រប់គ្រងបញ្ជីឈ្មោះ សំរង់ពិន្ទុ...។

**វិស័យសុខាភិបាល**ៈ គេប្រើប្រាស់ Computer ដើម្បីត្រួតពិនិត្យអ្នកជំងឺ ដូចជា ធ្វើតេស្ត ឈាម ពិនិត្យបេះដូង...

**វិស័យកសិកម្ម**ៈ គេប្រើប្រាស់ Computer ដើម្បីគ្រប់គ្រងគ្រឿងចក្រ និងផលិតផលគ្រឿងចក្រ...

**វិស័យគមនាគមន៍**ៈ គេប្រើប្រាស់ Computer ដើម្បីទំនាក់ទំនងគ្នាពីកន្លែងមួយទៅកន្លែងមួយ ពីតំបន់មួយ ទៅតំបន់មួយ .....

**វិស័យទេសចរណ៍**ៈ គេប្រើប្រាស់ Computer ដើម្បីគ្រប់គ្រងទិន្នន័យដូចជា ការគ្រប់គ្រង ភ្ញៀវទេសចរណ៍ ការគ្រប់គ្រងការលក់សំបុត្រយន្តហោះ មិនតែប៉ុណ្ណោះមកទល់ នឹងបច្ចុប្បន្ន នេះគឺ Computer អាចបង្ហាញព័ត៌មានផ្សេងៗ ការផ្សាយពាណិជ្ជកម្ម ទូរសារទំនាក់ទំនងទូរទាំងសកលលោក បានយ៉ាងរហ័ស និងលឿនបំផុតតាមរយៈប្រព័ន្ធ Internet និង E-mail។